ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

លេខ:១០២៩/២៦-១០-២០១២

សាលដីកា

លេខ:១០ ក្រ.ឧ/១៣-០២-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ១០២៩ចុះថ្ងៃទី២៦-១០-២០១២ រវាង:

១-ជនជាប់ចោទឈ្មោះ [redacted]ធីភុង ភេទស្រី អាយុ៣៣ឆ្នាំ មុខរបរលក់កាហ្វេ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិដូង ឃុំដូង ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted]ធូ មានកូន០៥នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី ២៦-៤-២០១២

លោក [redacted]ចន្ថា ជាមេធាវីការពារជនជាប់ចោទ ។

អ្នកបកប្រែភាសាវៀតណាមលោក កែវ សេង

២-ឈ្មោះ [redacted]ខេង ភេទស្រី អាយុ៥៧ឆ្នាំ។

៣-ឈ្មោះ [redacted]វិចិត្រ ភេទប្រុស អាយុ៣០ឆ្នាំ ។

<u>ត្រូវចោទពីបទ:</u> ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តិនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩-២០ ខែមេសា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៤ នៃក្រមព្រហ្មទណ្ឌ ។/.

១២៦





Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិវៀតណាម ទីលំនៅសព្វថ្ងៃសង្កាត់លេខ៧ ផ្លូវង្វៀងវ៉ាន់នី ទីក្រុងហូជីមិញ ។

**៦រឿងហេតុមានដូចតទៅៈ**

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី១៩-២០ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង៨និង៣០នាទីល្ងាច នៅផ្ទះសំណាក់ [redacted] ខេង ក្នុងភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង មានបទល្មើសព្រហ្មទណ្ឌមួយបង្កឡើងដោយឈ្មោះ វិន ធីកុង ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] វិចិត្រ បានចាប់ឃុំឃាំង និងបង្ខាំងលើជនរងគ្រោះឈ្មោះ [redacted] ដងភូណាម, ឈ្មោះ [redacted] ដាយធុង ,ឈ្មោះ [redacted] អាញ់គៀត ដើម្បីបង្ខំឲ្យជនរងគ្រោះទូរស័ព្ទឲ្យក្រុមគ្រួសារយកប្រាក់មកសង ដែលជនសង្ស័យបានអះអាងថា ជាប្រាក់ដែលជនរងគ្រោះបានខ្ចីលេងល្បែង ។ ក្រោយពីទទួលទូរស័ព្ទពីប្អូនប្រុសរួចមកឈ្មោះ ហ៊ុន ថងភូវិត ត្រូវជាបងរបស់ជនរងគ្រោះឈ្មោះ [redacted] ដងភូណាម បានសន្យារយៈពេលបីថ្ងៃ ហើយបានប្តឹងសមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ធីកុង ឈ្មោះ [redacted] ខេង ឈ្មោះ [redacted] វិចិត្រ ព្រមទាំងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១២ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៨ (ជ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅៈ

១-ក-សម្រេចផ្តន្ទាទោសលើៈ

-ឈ្មោះ [redacted] ធីកុង ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៨ឆ្នាំ (ប្រាំបីឆ្នាំ) ពីបទ ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ដោយស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩-២០ ខែមេសា ឆ្នាំ២០១២ បទល្មើសព្រហ្មទោសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៤ មាត្រា៩៣ និងមាត្រា៩៨នៃក្រមព្រហ្មទណ្ឌ ។

ខ-សម្រេចឲ្យជនជាប់ចោទៈ

-ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ

-ឈ្មោះ [redacted] ខេង ភេទស្រី អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ

រួចផុតពីការចោទប្រកាន់ ពីបទ ការចាប់ ការឃុំឃាំង និងការបង្ខាំង ដោយខុសច្បាប់ ដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩-២០ ខែមេសា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៤ នៃក្រមព្រហ្មទណ្ឌ ។

-ផ្អែកតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យលោកប្រធានពន្ធនាគារដោះលែងឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] ខេង ជាបន្ទាន់ ប្រសិនបើឈ្មោះទាំងពីរនាក់នេះមិនជាប់ចោទពីបទល្មើសអ្វីផ្សេងទេ ។

៣-សាលក្រមនេះជំនុំជម្រះ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីកុង ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] វិចិត្រ និងមេធាវីការពារជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ។

-បើកសិទ្ធិប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។/

១៧៧

Scanned with CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីភុង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៨(ជ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទី១(ក) ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ធីភុង បានឆ្លើយបញ្ជាក់ថា ឈ្មោះណាំ បានជួល២បន្ទប់ គឺបន្ទប់លេខ៨និងបន្ទប់លេខ១២ ជួលជាខែ ក្នុង១បន្ទប់មានតម្លៃ៦០ដុល្លាអាមេរិក តែខ្លួនមិនដឹងគាត់ដាក់មនុស្សបានប៉ុន្មានថ្ងៃទេ។ ខ្លួនមិនស្គាល់ជនរងគ្រោះទេ ហើយផ្ទះខ្លួនដាំបាយលក់ឲ្យកម្មករ ទើបឈ្មោះណាំទិញបាយឲ្យគេហូប ដោយពេលខ្លះខ្លួនយកទៅឲ្យនិងពេលខ្លះកម្មកររបស់ខ្លួនយកទៅឲ្យ តែខ្លួនមិនបានចាក់សោរបន្ទប់ ហើយមនុស្សនៅក្នុងនោះមើលទូរទស្សន៍ពុំមានដាក់ច្រវ៉ាក់ទេ គេចេញចូលបាន។ ឈ្មោះ ណាំ គាត់គ្រាន់តែឲ្យខ្លួនជួយយកលុយចំនួន២.០០០ដុល្លាឲ្យជនរងគ្រោះខ្ចី ក្នុងនោះមានលុយខ្លួន១០០០ដុល្លា ព្រោះឈ្មោះណាំធានាថា ក្មួយគាត់ទើបខ្លួនហ៊ានឲ្យខ្ចីហើយចម្លើយខ្លួននៅតុលាការថ្នាក់ក្រោមពុំមានអ្នកបកប្រែភាសាទេ ។ សំណូមពរសុំដោះលែងបាននៅក្រៅឃុំ ព្រោះខ្លួនត្រូវរកចិញ្ចឹមកូន៥នាក់ទៀត។

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន:

ពាក់ពន្ធ័រឿងនេះខ្ញុំយល់ឃើញថា ចម្លើយជនជាប់ចោទនៅសវនាការបដិសេធ តែបានសារភាពនៅសមត្ថកិច្ចនិងចំណាត់ការស៊ើបសួរ គឺរៀបរាប់ច្បាស់លាស់ថាបានប្រព្រឹត្ត គាត់សារភាពថា ចូលគ្នាជាមួយយាយណាំម្នាក់ចំនួន១០០០ (មួយពាន់) ដុល្លាអាមេរិក ឃើញថា គាត់ពិតចូលរួមជាមួយគ្នា ។ ជនរងគ្រោះជាយុវជនមានអាយុជាង២០ឆ្នាំ ការបង្ខាំងខ្លួនជនរងគ្រោះគ្មានការធ្វើទារុណកម្ម ហើយយកបាយទឹកឲ្យជម្មតា ឃាត់ខ្លួនជនរងគ្រោះដោយសារជំពាក់បំណុល នោះជាការបង្ខាំង តែមិនមែនបទបង្ខាំងមនុស្សមានស្ថានទម្ងន់ទោសមាត្រា២៥៤ នៃក្រមព្រហ្មទណ្ឌទេ គឺត្រូវនឹងបទបង្ខាំងមនុស្សខុសច្បាប់តាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ។ ការបង្ខាំង៤ថ្ងៃ ទោសត់រិតពី៣ឆ្នាំទៅ៥ឆ្នាំ សុំធ្វើការកែប្រែបទចោទតាមអង្គហេតុជាក់ស្តែង ។

-មេធាវីតំណាងឲ្យជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋាន

តាមភស្តុតាងនិងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឃើញថានៅសាលាដំបូង ជនជាប់ចោទបានសារភាព តែនៅសាលាឧទ្ធរណ៍បានបញ្ជាក់ថា យាយណាំជាអ្នកប្រព្រឹត្តដោយគ្រាន់តែឲ្យកូនក្តីខ្លួនយកលុយចំនួន២.០០០ដុល្លាទៅឲ្យជនរងគ្រោះខ្ចី ហើយយាយណាំបានឲ្យកូនក្តីខ្លួនចេញប្រាក់១០០០(មួយពាន់)ដុល្លាអាមេរិក គឺគាត់ធានាថាជាក្មួយគាត់ ។ ជនរងគ្រោះជាមនុស្សពេញវ័យនិងគ្មានការធ្វើទារុណកម្មទេ ការដាក់មនុស្សក្នុងបន្ទប់ជាការខុសឆ្គង តែជាសកម្មភាពរបស់យាយណាំ ដែលជាអ្នកជួលបន្ទប់របស់កូនក្តីខ្លួនទេ ។ កូនក្តីខ្លួនជាប់ពន្ធនាគារជាង១ឆ្នាំហើយ ដែលចម្លើយមានការភ្លេច សុំបន្ធូរបន្ថយទោសតាមមាត្រា៩៣នៃក្រមព្រហ្មទណ្ឌ។

-ក្រោយពីបានស្តាប់ការអានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីកុង ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ១៨ (ជ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទី១(ក) នៃសេចក្តីសម្រេចធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-នាសវនាការនេះ ជនជាប់ចោទឈ្មោះ [redacted] ធីកុង សារភាពថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ គ្រាន់តែខ្លួនបានជួលបន្ទប់ផ្ទះសំណាក់ឲ្យឈ្មោះបាណាំ ហើយបាណាំជាអ្នកនាំយកជនរងគ្រោះមកតែចម្លើយឈ្មោះ [redacted] ធីកុង សារភាពនៅដំណាក់កាលស៊ើបសួរថា ខ្លួនពិតជាបង្ខាំងជនរងគ្រោះរយៈពេល៣ថ្ងៃមែន ពេលឈ្មោះ [redacted] ដងភូណាម , ឈ្មោះ [redacted] ដាវេធុង និងឈ្មោះ [redacted] អាញ់គៀត ដោយសារជនរងគ្រោះរបស់គ្រួសារដៃ ដើម្បីឲ្យក្រុមគ្រួសារពួកគេបេកប្រាក់មកសងដល់ខ្លួន ។ ខ្លួនបានចេញប្រាក់ម្នាក់ពាក់កណ្តាលដោយប្តូរបាណាំឲ្យជនរងគ្រោះខ្ចីលេងល្បែង ដោយរកពុំមានធ្វើទារុណកម្មលើជនរងគ្រោះទេ សកម្មភាពរបស់ជនជាប់ចោទធ្វើឡើងដើម្បីទារបំណុលពីជនរងគ្រោះ ដែលតុលាការគួរកែប្រែបទចោទប្រកាន់ពីបទបង្ខាំងមនុស្សមានស្ថានទម្ងន់ទោស តាមមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ ទៅជាបទបង្ខាំងមនុស្សខុសច្បាប់តាមមាត្រា២៥៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌវិញ។

៣-ជនជាប់ចោទមិនធ្លាប់ត្រូវបានផ្តន្ទាទោស និងយល់ដឹងពីកំហុស ដោយសុំតុលាការបន្ធូរបន្ថយទោសបានត្រឡប់ទៅផ្ទះវិញ ព្រោះជាប់ពន្ធនាគារជាងមួយឆ្នាំ ហើយត្រូវរកចិញ្ចឹមកូន៥នាក់ទៀត គប្បីតុលាការពិចារណាលើការផ្តន្ទាទោសត្រឹមកំរិតអប្បបរិមា។

៤-សាលក្រមព្រហ្មទណ្ឌលេខ១៨ (ជ) ចុះថ្ងៃទី២៣-០៨-២០១២ របស់សាលាដំបូងខេត្តស្វាយរៀងបានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី១ (ក) គប្បីកែតម្រូវឡើងវិញតាមការយល់ឃើញខាងលើ ។

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីកុង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

២-កែប្រែបទចោទប្រកាន់ពីបទបង្ខាំងមនុស្សមានស្ថានទម្ងន់ទោស តាមមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ ទៅជាបទបង្ខាំងមនុស្សខុសច្បាប់តាមមាត្រា២៥៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨ (ជ) ចុះថ្ងៃទី២៣-០៨-២០១២ របស់សាលាដំបូងខេត្តស្វាយរៀងទុកជាបានការ លើកលែងតែចំណុចទី១-ក នៃសាលក្រមត្រង់ " ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ធីកុង ដាក់ពន្ធនាគារ៥ឆ្នាំ " ត្រូវកែប្រែជា " ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ធីកុង ដាក់ពន្ធនាគារ ៣ឆ្នាំវិញ តាមមាត្រា២៥៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ។ ចំណុចដទៃទៀតនៅរក្សាទុកជាបានការ ។

សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីកុង បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

**ក្រឡាបញ្ជី** — ហត្ថលេខា: [redacted]

**ចៅក្រមប្រឹក្សា** — ហត្ថលេខា: [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ** — ហត្ថលេខា: [redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ៣០ ខែ 4 ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

១២៩



Scanned with CamScanner